26 January 2023

💡 Tips of the Week



(Sin in Islam, Part II)

(Sin in Islam, Part II)

وقال تعالى: ﴿ وَلَا تَعَاوَنُوا عَلَى الْإِثْمِ وَالْعُدْوَانِ ۚ ﴾[سورة المائدة(2)]
អល់ឡោះបានមានបន្ទូលថា : " ចូរពួកអ្នកកុំជួយគ្នាលើទង្វើបាបកម្ម និងទង្វើ ដែលនាំ អោយក្លាយជាសត្រូវនឹងគ្នា" (អាល់ម៉ាអ៊ីហ្ទះ : ២)

قال اللَّهَ تعالى: ﴿ وَاسْتَغْفِرْ لِذَنْبِكَ وَلِلْمُؤْمِنِينَ وَالْمُؤْمِنَاتِ ۗ ﴾[سورة محمد(19)]
អល់ឡោះបានមានបន្ទូលថា " ចូរអ្នក(មូហាំម៉ាត់)សុំអភ័យទោសពីម្ចាស់របស់ អ្នកចំពោះ បាបកម្មរបស់អ្នក និងអ្នកអ៊ីស្លាមទាំងប្រុសទាំងស្រី"
(មូហាំម៉ាត់ : ១៩)

قال اللَّهَ تعالى :﴿ قل يا عبادي الذين أسرفوا على أنفسهم لا تقنطوا من رحمة اللَّه إن اللَّه يغفر الذنوب جميعاً، إنه هو الغفور الرحيم ﴾. سورة الزمر(53)
អល់ឡោះបានមានបន្ទូលថា : ឱបណ្តាខ្ញុំរបស់យើងដែលបានបំពានលើខ្លួនឯង (តាមរយៈការសាងទង្វើបាបកម្ម) ចូរពួកអ្នកកុំអស់សង្ឃឹមពីក្តីករុណារបស់ អល់ឡោះ។អល់ឡោះពិតជាអភ័យទោសទាំងអស់(ចំពោះអ្នកសារភាពកំហុស)។ ពិតណាស់ ទ្រង់គឺជាអ្នក

Caption

អភ័យទោស និងអាណិតអាសូរបំផុត។ (អាល់ហ្សូមើរ : ៥៣)

وقال تعالى: ﴿وَمَا كَانَ اللَّهُ لِيُعَذِّبَهُمْ وَأَنْتَ فِيهِمْ ۚ وَمَا كَانَ اللَّهُ مُعَذِّبَهُمْ وَهُمْ يَسْتَغْفِرُونَ﴾[سورة الأنفال(33)]
អល់ឡោះបានមានបន្ទូលថា " អល់ឡោះនឹងមិនដាក់ទណ្ឌកម្មចំពោះពួកគេឡើយ ខណៈដែលអ្នកនៅក្នុងចំណោមពួកគេ ហើយអល់ឡោះក៏មិនដាក់ទណ្ឌកម្មចំពោះ ពួកគេដែរ ខណៈដែលពួកគេសុំអភ័យទោស" (អាល់អាំហ្វាល : ៣៣)។

وقال تعالى: ﴿وَالَّذِينَ إِذَا فَعَلُوا فَاحِشَةً أَوْ ظَلَمُوا أَنْفُسَهُمْ ذَكَرُوا اللَّهَ فَاسْتَغْفَرُوا لِذُنُوبِهِمْ وَمَنْ يَغْفِرُ الذُّنُوبَ إِلَّا اللَّهُ وَلَمْ يُصِرُّوا عَلَىٰ مَا فَعَلُوا وَهُمْ يَعْلَمُونَ﴾[سورة آل عمران(135)]

អល់ឡោះបានមានបន្ទូលថា "ពួកអ្នកដែលនៅពេលពួកគេប្រព្រឹត្តនូវទង្វើអាក្រក់ (បាបកម្មធំ) ឬបានបំពានលើខ្លួនឯង(ដោយប្រព្រឹត្តនូវបាបកម្មតូច) ហើយ នឹកឃើញទៅចំពោះអល់ឡោះ និងសុំអភ័យទោសចំពោះបាបកម្មរបស់ពួកគេ ដោយពួកគេដឹងថា គ្មានអ្នកណាអាចអភ័យទោសអោយពួកគេក្រៅពីអល់ឡោះ ឡើយ ហើយពួកគេមិនបន្តបំពានចំពោះអ្វីដែលពួកគេបានសាង ដោយពួកគេ ដឹងថា (អល់ឡោះនឹងអភ័យទោសអោយពួកគាត់)" (អាលីអ៊ិមរ៉ន : ១៣៥)

وقال تعالى: ﴿ ولا تستوي الحسنة ولا السيئة، ادفع بالتي هي أحسن، فإذا الذي بينك وبينه عداوة كأنه ولي حميم؛ وما يلقاها إلا الذين صبروا ، وما يلقاها إلا ذو حظ عظيم ﴾ .سورة فصلت(34-35)

អល់ឡោះបានមានបន្ទូលថា: " ទង្វើល្អ និងទង្វើអាក្រក់មិនស្មើគ្នាឡើយ។ ចូរ អ្នកទប់ទល់នឹងទង្វើអាក្រក់ដោយសីលធម៌ល្អប្រសើរ។ ប្រសិនបើអ្នកធ្វើដូច្នោះ នៅពេល ដែលអ្នកមានជម្លោះជាមួយអ្នកណាម្នាក់នោះ គាត់នឹងក្លាយដូចជាមិត្ត ជាទី ស្រលាញ់របស់អ្នក។ គ្មានអ្នកណាអាចធ្វើដូច្នោះបានទេ មានតែពួក អ្នកអត់ធ្មត់ហើយគ្មានអ្នកណាម្នាក់ធ្វើដូច្នោះបានឡើយមានតែពួកអ្នកដែលមានភព្វសំណាង ដ៏ធំធេង។ (ហ្វ៊ូស្ស៊ីឡាត់: ៣៤-៣៥)

~Sin គឺជា Hima របស់អល់ឡោះជាម្ចាស់

(សំរាប់បាបកម្ម مَعْصِيَةٍ ឬ إثم)

(Sahih al-Bukhari 2051)

~Sin នៅពេលបងប្អូនរបស់យើងបានប្រព្រឹត្តវា បន្ទាប់មកយើងបានទៅបង្គាប់ទៅលើពួកគេ ដូចនេះយើងនឹងមិនស្លាប់ទេរហូតដល់បានប្រព្រឹត្តបាបកម្មនោះ

(សំរាប់បាបកម្ម ذَنب)

(Jami` at-Tirmidhi 2505 Da'if)

~Sin សំរាប់ជនអីស្លាមមិនមានកាតព្វកិច្ចស្តាប់ និងប្រតិបត្តិតាមនោះការងារទេទោះបីជាឪពុកម្តាយ ឬមេដឹកនាំបានបញ្ជាក៏ដោយ ពីព្រោះថាអ្នកអីស្លាមមិនអាចបំពានច្បាប់នៃគម្ពីរដែលអល់ឡោះជាម្ចាស់បានបញ្ចុះមករួចនោះទេ

(សំរាប់បាបកម្ម مَعْصِيَةٍ ឬ إثم)

(Riyad as-Salihin 663)

~Sin អាចកើតមានរៀងរាល់ថ្ងៃ ដូចនេះចូរបួងសួងឲ្យបានច្រើននៃបាបកម្មរបស់ខ្លួនយើង បាបកម្មដែលមិនទាន់បានសាង បាបកម្មដែលនឹងសាងនៅខាងមុខ បាបកម្មដែលសាងដោយលាតត្រដាង និង លាក់បាំង បាបកម្មដែលសាងច្រើនដង និងបាបកម្មដែលទ្រង់ដឹងពីខ្ញុំ

" اللَّهُمَّ اغْفِرْ لِي مَا قَدَّمْتُ وَمَا أَخَّرْتُ ، وَمَا أَسْرَرْتُ وَمَا أَعْلَنْتُ ، وَمَا أَسْرَفْتُ ، وَمَا أَنْتَ أَعْلَمُ بِهِ مِنِّي ، أَنْتَ
الْمُقَدِّمُ ، وَأَنْتَ الْمُؤَخِّرُ ، لا إِلَهَ إِلا أَنْتَ "

Caption

(ឱអល់ឡោះ! សូមអភ័យទោសដល់ខ្ញុំនូវបាបកម្មដែលខ្ញុំបានសាងរួច និង បាបកម្មដែលខ្ញុំមិនទាន់បានសាង បាបកម្មដែលខ្ញុំសាងដោយលាតត្រដាង និង លាក់បាំង បាបកម្មដែលខ្ញុំសាច្រើនដង និងបាបកម្មដែលទ្រង់ដឹងពីខ្ញុំ ទ្រង់គឺជា អ្នកដំបូងគេ និងជាអ្នកចុងក្រោយគេ គ្មានទេម្ចាស់ដែលត្រូវគេគោរពសក្ការៈដ៏ ត្រឹមត្រូវមានតែទ្រង់)"

(Riyad as-Salihin 1424)

~Sin អាចកើតមានចំពោះម្ចាស់ផ្ទះនៅពេលគ្មានអ្វីទទួលភ្ញៀវ

(សំរាប់បាបកម្ម إثم)

(Riyad as-Salihin 707)

~Sin អាចកើតមានចំពោះការយក ឬប្រមូលលុយ Zakat លើសចំនួនដែលត្រូវបង់
(Jami` at-Tirmidhi 646)

~Sin មិនអាចកើតចំពោះការលក់ដូរនៅរដូវបុណ្យ Hajj ឬនៅកន្លែងនោះទេ
(សំរាប់បាបកម្ម إثم)
(al-Quran 2:198)
(Riyad as-Salihin 1284)

~Sin នឹងកើតឡើងចំពោះអ្នក mu'min ដែលមិនឆ្លើយតប សាឡាមគ្នាទៅវិញទៅមក នៅពេលពួកគេបោះបង់គ្នាលើស ពី 3 ថ្ងៃ
(សំរាប់បាបកម្ម إثم)
(Riyad as-Salihin 1597)

~Sin ជនមួយដែលបានរារាំងអ្នក ដែលមានចំណែកក្នុងទ្រព្យសម្បត្តិរបស់គាត់មិនអោយគេទទួលបានចំណែក គឺគ្រប់ គ្រាន់ហើយទង្វើនោះនាំឲ្យមានបាបកម្ម
(សំរាប់បាបកម្ម إِثْمٌ)

Caption

(Riyad as-Salihin 294)

~Sin ជនមួយដែលបោះបង់ចោលអ្នកដែលគាត់មានភារកិច្ចផ្គត់ផ្គង់អាហារ ឬចិញ្ចឹមដល់គេ គឺគ្រប់គ្រាន់ហើយទង្វើនោះនាំឲ្យមានបាបកម្ម
(សំរាប់បាបកម្ម إِثْمٌ)
(Riyad as-Salihin 294)

~Sin ជនដែលនៅជិតវាប្រៀបដូចជាសត្វចៀមនៅជិតវាលស្មៅដែលអាចចូលទៅក្នុងកន្លែងនោះពេលណាមួយ
(សំរាប់បាបកម្ម مَعْصِيَةٍ ឬ إثم)
(Sahih al-Bukhari 2051)

~Sin ជនណាម្នាក់បើអល់ឡោះជាម្ចាស់បានបិទបាំងសំរាប់ពួកគេនោះ គឺវាស្ថិតទៅលើអល់ឡោះជាម្ចាស់ថាត្រូវដាក់ទណ្ឌកម្ម ឬអភ័យទោសដល់ពួកគេ

(Sahih al-Bukhari 4894)

~Sin ជនដែលប្រព្រឹត្តវាបន្ទាប់មកទទួលទណ្ឌកម្ម ដូចនេះវា ជាការលាងកំហុសរបស់ពួកគេ

(Sahih al-Bukhari 6784)

~Sin និងប្រការទាក់ទងនឹងការរួមភេទ (يَرْفُثْ) ត្រូវបានហាមឃាត់មិនប្រព្រឹត្តនៅពេលបុណ្យ Hajj

(សំរាប់បាបកម្ម فساق)

(Riyad as-Salihin 1274)

~Sin និងកំហុសកើនឡើងច្រើននឹងធ្វើឲ្យមនុស្សស្លាប់ ឬវលាយសាបសូន្យ គឺពួកគេនឹងមិនត្រូវបានគេអភ័យទោសឲ្យទេ

(Sunan Abi Dawud 4347)

Caption

~ជនដែលបោះបង់ប្រការដែលមិនច្បាស់លាស់ក្រែងលោ ប្រព្រឹត្តអំពើបាបកម្ម នឹងប្រាកដជាគេចអំពីអ្វីដែលមិនស្របច្បាប់យ៉ាងពិតប្រាកដ

(សំរាប់បាបកម្ម إثم)

(Sahih al-Bukhari 2051)

~កាតព្វកិច្ចត្រូវស្តាប់ និងប្រតិបត្តិតាមមេដឹកនាំបើអ្វីៗទាំងនោះមិនពាក់ព័ន្ធនឹងបាបកម្មនោះទេ តែអីស្លាមមិនអនុញ្ញាតិឲ្យប្រតិបត្តិតាមចំពោះអ្វីមួយដែលនាំឲ្យមានបាបកម្មឡើយ

(សំរាប់បាបកម្ម مَعْصِيَةٍ ឬ إثم)

(Riyad as-Salihin 663)

~ជាកាតព្វកិច្ចចំពោះបុគ្គលអ៊ីស្លាមគឺការស្ដាប់ និងប្រតិបត្តិតាមមេដឹកនាំទាំង អ្វីដែលគាត់ពេញចិត្ត និងមិនពេញចិត្ត លើកលែងតែមេដឹកនាំនោះប្រើអោយ ប្រព្រឹត្តនូវទង្វើបាបកម្ម។ ប្រសិនបើគាត់ត្រូវគេប្រើអោយសាងបាបកម្ម គាត់មិន ត្រូវស្ដាប់ និងប្រតិបត្តិតាមឡើយ

(សំរាប់បាបកម្ម مَعْصِيَةٍ ឬ إثم)

(Riyad as-Salihin 663)

~ចូរជៀសវាងបាបកម្មធំៗ នៅពេលដែលអ្នកអីស្លាមចង់លុបលាងបាបកម្មរបស់ពួកគេ ដូចនេះពួកគេសឡ្ញាតកាតព្វកិច្ចដោយយកទឹក Wudu’ ត្រឹមត្រូវ សឡ្ញាតដោយនឹងនរ khushu’ និងរូកុដោយត្រឹមត្រូវវានឹងជំរុះចោលនូវបាបកម្មកាលពីមុនៗមក ហើយវានឹងកើតពេញមួយឆ្នាំ

(សំរាប់បាបកម្ម ذَنب)

(Riyad as-Salihin 1046)

~ការឲ្យសឡ្ញាមគ្នាទៅវិញទៅមករវាងអ្នក mu’min ដែលបានបោះបង់គ្នាលើស ពី 3 ថ្ងៃ

Caption

ដែលអ្នកអោយសាឡ្ញាមនោះនឹងចេញផុតពីបាបកម្មនៃការបោះបង់គ្នា

(សំរាប់បាបកម្ម إثم ឬបាបកម្មការបោះបង់គ្នា)

(Riyad as-Salihin 1597)

~ការធ្វើទង្វើអាក្រក់មួយនឹងត្រូវទទួលបានបាបកម្មមួយ ឬយើងអាចអភ័យទោស ហើយការធ្វើទង្វើល្អមួយនឹងទទួលបានផលបុណ្យដប់ឬលើសពីនេះ

(សំរាប់បាបកម្ម سَيِّئَةٍ)

(Riyad as-Salihin 413)

~ការស្រលាញ់ភេទដូចគ្នា គឺជាបាបកម្ម

(សំរាប់បាបកម្ម السيئات)

(al-Quran 11:78)

~Zakat គឺជាភាពមិនស្អាតស្អំមកពីមនុស្សលោក ឬក៏ជាការ លាងទោសកំហុសនៃបាបកម្ម របស់ពួកគេ

(Sunan an-Nasa'i 2609)

~អីស្លាមបានអនុញ្ញាតិឲ្យបួងសួងសុំខមាលទោសចំពោះសព

(Riyad as-Salihin 935)

~រ៉ស៊ូលុលឡោះ ﷺ បានស្បថថា ប្រសិនបើពួកអ្នកគ្មានបាបកម្មទេ នោះ អល់ឡោះនឹងបំបាត់ពួកអ្នក ដោយជំនួសពួកអ្នកវិញនូវក្រុមមួយដែលសាង បាបកម្មទៅចំពោះទ្រង់ ហើយពួកគេសុំអភ័យទោសពីអល់ឡោះ ដើម្បីទ្រង់នឹង អភ័យទោសអោយពួកគេ

(Riyad as-Salihin 1871)

~រ៉ស៊ូលុលឡោះ ﷺ តែងតែជ្រើសរើសអ្វីដែលស្រួល នៅពេលគេផ្តល់សិទ្ធិអោយគាត់ជ្រើសរើសរវាងប្រការពីរយ៉ាង ហើយបើវាមិនមានបាបកម្មទេនោះ

(សំរាប់បាបកម្ម إثم)

(Riyad as-Salihin 641)

Caption

~រ៉ស៊ូលុលឡោះគេចពីអំពើបាបនៅក្នុងកិច្ចការ ហើយជ្រើសរើសយកការងារណាដែលងាយស្រួល

(Sahih Muslim 2327 d)

~Mu’adh (Sahabat) ខ្លាចបាបកម្មនៃការលាក់បាំងនៃចំណេះវិជ្ជា

(សំរាប់បាបកម្ម إثم)

(Riyad as-Salihin 415)

~Allāh នឹងយ៉ាហូទី ឬណាសរ៉នីម្នាក់ អោយអ្នកអ៊ីស្លាមគ្រប់ៗគ្នា ហើយមានបន្ទូលថាម្នាក់នេះជាអ្នកលោះអ្នកពីនរក

(សំរាប់បាបកម្ម ذَنب)

(Riyad as-Salihin 432)

~Allāh នឹងយកបាបកម្មប៉ុនភ្នំរបស់អីស្លាមទៅដាក់ឲ្យយ៉ាហូទី ឬណាសរ៉នីដោយសាអល់ឡោះជាម្ចាស់អភ័យទោស សំរាប់អ្នកអីស្លាម

(សំរាប់បាបកម្ម ذَنب)

(Riyad as-Salihin 432)

~Allāh នឹងបំបាត់ពួកអ្នកដែលមិនសាងបាបកម្មដោយជំនួសពួកអ្នកវិញនូវក្រុមមួយដែលសាង បាបកម្មទៅចំពោះទ្រង់ ហើយពួកគេសុំអភ័យទោសពីអល់ឡោះ ដើម្បីទ្រង់នឹងអភ័យទោសអោយពួកគេ

(សំរាប់បាបកម្ម ذَنب)

(Riyad as-Salihin 1871)

Caption

©Sin បានលើកឡើងជាពាក្យនៅក្នុងគម្ពីរ និង Hadith មានដូចជា៖

1.dhanb
2.khaṭīʾa khataayaa បាបកម្មដែលធ្វើដោយមានការតាំងចិត្តជាមុន

3.Junah/Haraj
4.ithm បាបកម្មដ៏ធំ

5.Jurm ដែលអ្នកប្រព្រឹត្តហៅថា mujrim

6.khiṭʾ បាបកម្មទូទៅ

7.fasiq
8.jinaaya

9.al-Kabirah (major sins)
10.al-Lamam (minor sins)
11.ma’siya
12.sayyiah

» al-Kabirah និង al-Lamam

បណ្តាអ្នកដែលចៀសវាងពីបាបកម្មធំៗ និងអំពើអសីល-ធម៌ផ្សេងៗ ក្រៅពីបាបកម្មតូចតាចនោះ ពិតប្រាកដណាស់ ម្ចាស់ របស់អ្នកគឺជាអ្នកទូលំទូលាយក្នុងការអភ័យទោស។ ទ្រង់ដឹងបំផុត ពីលក្ខណៈរបស់ពួកអ្នក ខណៈដែលទ្រង់បានបង្កើតពួកអ្នកពីដី និង នៅពេលពួកអ្នកជាទារកនៅក្នុងពោះម្ដាយរបស់ពួកអ្នក។ ដូច្នេះ ចូរ ពួកអ្នកកុំមានមោទនភាពចំពោះខ្លួនឯងថាជាអ្នកស្អាតស្អំឱ្យសោះ ព្រោះទ្រង់ដឹងបំផុតចំពោះអ្នកដែលកោតខ្លាចទ្រង់។
(al-Quran 53:32)

from Ibn 'Abbas (regarding this Ayah): Those who avoid great sins and Al-Fawahish except Al-Lamam (minor sins) (53:32). He said: "The Prophet (ﷺ) said: 'Your forgiveness, O Allah is so ample, and which of Your worshipers has not committed Al-Lamam (minor sins)!'"
(Jami` at-Tirmidhi 3284)

»dhanb ៖ ប្រើសំរាប់អំពើបាបដែលសាហាវយង់ឃ្នង ។

1.វាត្រូវបានគេចាត់ទុកថាជាការប្រព្រឹត្តទាំងមានគោលបំណង និងគ្មានគោលបំណង
2.ការរត់ចោលជួរប្រយុទ្ធ
(al-Quran 3:15-16, 39:53)

»ithm ៖ ប្រើសំរាប់ប្រការដូចជា ៖

1.ប្រការ Shirk

2.ការចោទប្រកាន់ទៅលើប្រពន្ធរបស់ខ្លួនដើម្បីទទួលបានទ្រព្យសម្បត្តិដោយស្របច្បាប់ វានោះគឺជា ithm

3.ប្រការ Haram ការប្រព្រឹត្តអំពើមិនស្របច្បាប់ និងការហាមឃាត់របស់សាសនា ឬប្រពៃណី ដូចជា ការបរិភោគ និងផឹកអាហារដែលសាសនាបានហាមឃាត់ ។

(al-Quran 2:73, 4:20, 4:50, 4:111-112)

»khaṭīʾah៖ ប្រើសំរាប់កំហុសតូចតាច ឬកំហុសមួយ

1.ប្រើសំរាប់កំហុសតូចជាង ithm

2.ប្រើជាមួយនឹង ithm

3.ជួនកាលប្រើសំរាប់បាបកម្មធំ ដូចជាការសំលាប់កូនរបស់ខ្លួនដោយសាខ្លាចក្រ

Caption

(al-Quran 4:112, 17:31)

»Jurm៖ ប្រើសំរាប់កំហុសដូចទៅនឹង dhanb

1.synonym of dhanb

2.ការព្រហើនទៅលើអ្នកមានជំនឿ

(al-Quran 83:29)

»Junah៖ ប្រើសំរាប់កំហុសដែលបង្ហាញថាត្រូវតែទទួលទណ្ឌកម្ម

1.មានអត្ថន័យស្រដៀងនឹង ithm

2.ប្រើសំរាប់ទៅលើការរៀបការ និងការលែងលះ

3.ការសំលាប់សត្វនៅកំឡុងពេលស្លៀក Ihram
(al-Quran 2:235)

»ផ្សេងៗ ...

•Dua សុំខមាលទោសអំពីបាបកម្ម

1.គួរសុំខមាលទោសនៅពេលស៊ូជូត

ពិតណាស់ រ៉ស៊ូលុលឡោះ ﷺ តែងតែបួងសួង នៅក្នុង ការស៊ូជោតរបស់លោកថា :
" اللَّهُمَّ اغْفِرْ لي ذَنْبِي كُلَّهُ دِقَّهُ وَجِلَّهُ ، وَأَوَّلَهُ وَآخِرَهُ ، وَعَلانِيَتَهُ وَسِرَّهُ "
(ឱអល់ឡោះ! សូមអភ័យទោសនូវបាបកម្មទាំងអស់របស់ខ្ញុំ ទាំងតូច ទាំងធំ មុន និងក្រោយ ទាំងលាតត្រដាង និងលាក់បាំង)"
(សំរាប់បាបកម្ម ذَنْب)
(Riyad as-Salihin 1429)

Caption
2.Master of Forgiveness (Sayyid al-Istighfar)

អំពី ស្សាត់ហ្សាត ពិន អោវស៏ رضي الله عنه ថា : ណាពី ﷺ បានមានប្រសាសន៏ថា : ពាក្យដ៏ល្អបំផុតសំរាប់ការសុំអភ័យទោសគឺ :
" اللَّهُمَّ أَنْتَ رَبِّي لا إِلَهَ إِلا أَنْتَ خَلَقْتَنِي وَأَنَا عَبْدُكَ ، وَأَنَا عَلَى عَهْدِكَ وَوَعْدِكَ مَا اسْتَطَعْتُ ، أَعُوذُ بِكَ مِنْ شَرِّ مَا صَنَعْتُ ، أَبُوءُ لَكَ بِنِعْمَتِكَ عَلَيَّ ، وأَبُوءُ بِذَنْبِي ، فَاغْفِرْ لِي ، فَإِنَّهُ لا يَغْفِرُ الذُّنُوبَ إِلا أَنْتَ "
"ឱអល់ឡោះ! ទ្រង់ជាម្ចាស់របស់ខ្ញុំ។ គ្មានទេម្ចាស់ដែលត្រូវគេគោរពសក្ការៈដ៏ ត្រឹមត្រូវមានតែទ្រង់។ ទ្រង់ជាអ្នកបង្កើតខ្ញុំ ហើយខ្ញុំជាបំរើរបស់ទ្រង់ ខ្ញុំស្ថិតនៅ លើកិច្ចសន្យារបស់ទ្រង់តាមលទ្ធភាពរបស់ខ្ញុំ ខ្ញុំសុំពីទ្រង់មេត្តាបញ្ចៀសខ្ញុំពីប្រការ អាក្រក់ដែលខ្ញុំបានសាង ខ្ញុំ

ទទួលស្គាល់ឧបការគុណរបស់ទ្រង់មកចំពោះខ្ញុំ ហើយ ខ្ញុំទទួលស្គាល់នូវបាបកម្មរបស់ខ្ញុំ ហេតុនេះសូមទ្រង់អភ័យទោសអោយខ្ញុំផង ព្រោះគ្មានអ្នកណាម្នាក់អាចអភ័យទោស អោយខ្ញុំក្រៅពីទ្រង់ឡើយ" បុគ្គលណា សូត្រវានៅពេលពេលថ្ងៃដោយជឿជាក់ចំពោះវា ហើយស្លាប់នៅក្នុងថ្ងៃនោះ មុនពេលល្ងាចនោះ គាត់គឺជាអ្នកឋានសួគ៌។ ហើយបុគ្គលណា សូត្រវា នៅពេល យប់ដោយមានជំនឿចំពោះវា ហើយគាត់ស្លាប់មុនពេលភ្លឺ គាត់គឺជាអ្នក ឋាន សួគ៌"

(សំរាប់បាបកម្ម ذَنب)

(Riyad as-Salihin 1875)


Caption

3.

អំពី អ៊ីបនូម៉ាស៊្វូទ رضي الله عنه ថា : រ៉សូលុលឡោះ ﷺបានមានប្រសាសន៍ថា : "បុគ្គលណាសូត្រថា :

" أَسْتَغْفِرُ اللهَ الَّذِي لا إِلَهَ إِلا هُوَ الحَيُّ القَيُّومُ وَأَتُوبُ إِلَيهِ "

"ខ្ញុំសុំអភ័យទោសពីអល់ឡោះ ដែលគ្មានម្ចាស់ណាដែលត្រូវគេគោរពសក្ការៈ ដ៏ត្រឹមត្រូវក្រៅពីទ្រង់ឡើយ ទ្រង់ជាអ្នករស់ជាអមត និងមិនត្រូវការពឹងពាក់ អ្នកណាឡើយ ខ្ញុំសុំសារភាពកំហុសទៅចំពោះទ្រង់ " គេនឹងអភ័យទោសអោយ គាត់ ទោះជាបានរត់ចោលជួរនៅក្នុងសមរភូមិក៏ដោយ"

(សំរាប់បាបកម្ម ذَنب)

(Riyad as-Salihin 1874)

4.ការសូត្រមួយថ្ងៃ 100 ដងនៃឃ្លាខាងក្រោមនឹងលុបលាងបាបកម្មរបស់ពួកគេទោះបីមានច្រើនដូចពពុះសមុទ្រក៏ដោយ

سُبْحَانَ اللَّهِ وَبِحَمْدِهِ

(សំរាប់បាបកម្ម خَطَايَا)

(Mishkat al-Masabih 2296)

5.

គាត់رضي الله عنه បាននាយការណ៍ថា : ពិតណាស់រ៉ស៊ូលុលឡោះ ﷺបានមានប្រសាសន៍ថា : " បុគ្គលណាសូត្រថា :

" لا إلَهَ إلا اللهُ وَحْدَهُ لا شَرِيكَ لَهُ ، لَهُ المُلْكُ وَلَهُ الحَمْدُ ؛ وَهُوَ عَلَى كُلِّ شَيْءٍ "

គ្មានទេម្ចាស់ដែលត្រូវគេគោរពសក្ការៈដ៏ត្រឹមត្រូវ មានតែអល់ឡោះម្នាក់គត់ គ្មានទេស៊ីរិកទៅចំពោះទ្រង់ ទ្រង់ជាម្ចាស់កម្មសិទ្ធិ និងជាអ្នកត្រូវគេសរសើរ ហើយទ្រង់គឺជាអ្នកមានអានុភាពលើអ្វីៗទាំងអស់" ក្នុងមួយថ្ងៃ១០០ដង គាត់នឹង ទទួលផលបុណ្យដូចជាការដោះលែងទាសករ ១០នាក់ ហើយគេកត់ត្រាអោយ គាត់ នូវទង្វើល្អ១០០ និងបោសសំអាតចោល នូវទង្វើអាក្រក់ចំនួន១០០ មិនតែ ប៉ុណ្ណោះគាត់ទទួលបាននូវការការពារពីបិសាចស្សៃតន នៅថ្ងៃនោះរហូតដល់ល្ងាច ហើយគ្មានអ្នកណាម្នាក់អាចមានទង្វើដែលល្អជាងគាត់នោះទេ លើកលែងតែអ្នក ដែលសូត្រលើសគាត់"

(សំរាប់បាបកម្ម سَيِّئَةٍ)

(Riyad as-Salihin 1410)

6.

ចូរអ្នកបួងសួងថា :

" اللَّهُمَّ اغْفِرْ لِي ، وَارْحَمْنِي وَاهْدِنِي ، وَارْزُقْنِي "

(ឱអល់ឡោះ! សូមទ្រង់អភ័យទោសដល់ខ្ញុំ អាណិតអាសូរខ្ញុំ បង្ហាញផ្លូវខ្ញុំ និង ផ្តល់លាភសក្ការៈដល់ខ្ញុំ

(Riyad as-Salihin 1414)

7.
ចូរសូត្រថា :

أَسْتَغْفِرُ الله أَسْتَغْفِرُ الله
(ខ្ញុំសុំអភ័យទោស ពីអល់ឡោះ ខ្ញុំសុំអភ័យទោសពីអល់ឡោះ)"
(Riyad as-Salihin 1415)

8.

បុគ្គលណាសូត្រថា :
سُبْحَانَ الله
(អល់ឡោះដ៏មហាបរិសុទ្ធ) ក្រោយពេលសឡាត ចំនួនពាពដង សូត្រថា
الحَمْدُ لله
(រាល់ការសរសើរទាំងឡាយគឺសំរាប់ អល់ឡោះ) សូត្រថា
اللهُ أَكْبَرُ
(អល់ឡោះធំធេងបំផុត)ចំនួនពាពដង និងសូត្រ បង្គ្រប់១០០ថា :
Caption
" لا إلهَ إلا اللهُ وَحْدَهُ لا شَرِيكَ لَهُ ، لَهُ المُلْكُ وَلَهُ الحَمْدُ ، وَهُوَ عَلَى كُلِّ شَيْءٍ قَدِيرٌ"
(គ្មានទេម្ចាស់ដែលត្រូវគេគោរពសក្ការះដ៏ត្រឹមត្រូវ មានតែអល់ឡោះម្នាក់គត់ គ្មានទេស៊ីរិកទៅចំពោះទ្រង់ ទ្រង់ជាម្ចាស់កម្មសិទ្ធិ ជាអ្នកត្រូវគេសរសើរ ហើយ ទ្រង់គឺជាអ្នកមានអានុភាពលើអ្វីៗទាំងអស់)

គេនឹងអភ័យទោសអោយគាត់ ទោះជាបាបកម្មរបស់ គាត់ច្រើនដូចពពុះទឹកសមុទ្រក៏ដោយ"
(សំរាប់បាបកម្ម خَطَايَا)
(Riyad as-Salihin 1419)

9.

អំពី អាលីرضي الله عنهថា : រ៉សូលុលឡោះ ﷺនៅពេលសឡាត នៅចន្លោះរវាង តាស្ហះ ហ៊ុទ(តះយ៉ាត់) និងការអោយសាឡាម លោកតែងសូត្រថា:

" اللَّهُمَّ اغْفِرْ لِي مَا قَدَّمْتُ وَمَا أَخَّرْتُ ، وَمَا أَسْرَرْتُ وَمَا أَعْلَنْتُ ، وَمَا أَسْرَفْتُ ، وَمَا أَنْتَ أَعْلَمُ بِهِ مِنِّي ، أَنْتَ
الْمُقَدِّمُ ، وَأَنْتَ الْمُؤَخِّرُ ، لا إِلَهَ إِلا أَنْتَ "

(ឱអល់ឡោះ! សូមអភ័យទោសដល់ខ្ញុំនូវបាបកម្មដែលខ្ញុំបានសាងរួច និង បាបកម្មដែលខ្ញុំមិនទាន់បានសាង បាបកម្មដែលខ្ញុំសាងដោយលាតត្រដាង និង លាក់បាំង បាបកម្មដែលខ្ញុំសាច្រើនដង និងបាបកម្មដែលទ្រង់ដឹងពីខ្ញុំ ទ្រង់គឺជា អ្នកដំបូងគេ និងជាអ្នកចុងក្រោយគេ គ្មានទេម្ចាស់ដែលត្រូវគេគោរពសក្ការៈដ៏ ត្រឹមត្រូវមានតែទ្រង់)"
(Riyad as-Salihin 1424)

10.
ណាពី ﷺ នៅពេលអានស៊ូជោត និងរូកុ លោកភាគច្រើនសូត្រថា :

" سُبْحَانَكَ اللَّهُمَّ رَبَّنَا وبِحَمْدِكَ ، اللَّهُمَّ اغْفِرْ لِي "
(ឱអល់ឡោះ! ទ្រង់ដ៏មហាបរិសុទ្ធ ជាម្ចាស់របស់ពួកយើង រាល់ការសរសើរ ទាំងឡាយ គឺសំរាប់ទ្រង់។ ឱអល់ឡោះ! សូមទ្រង់អភ័យទោសដល់ខ្ញុំផង)"
(Riyad as-Salihin 1425)

11.ការបួងសួងដើម្បីលុបលាងបាបកម្មសំរាប់អ្នកស្លាប់បាត់ទៅ

អំពី អាពូ អាប់ទុលរ៉ោះម៉ាន អាហ្វ ពិន ម៉ាលិកرضي الله عنهថា : រ៉សូលុលឡោះ ﷺបានសឡាតអោយសពម្នាក់ ហើយខ្ញុំបានទន្ទេញចាំនូវការបួងសួងរបស់ លោក ខណៈដែល លោកសូត្រថា:

" اللَّهُمَّ اغْفِرْ لَهُ وَارْحَمْهُ ، وَعَافِهِ وَاعْفُ عَنْهُ ، وَأَكْرِمْ نُزُلَهُ ، وَوَسِّعْ مُدْخَلَهُ ، وَاغْسِلْهُ بِالمَاءِ وَالثَّلْجِ وَالبَرَدِ ، وَنَقِّه مِن الخَطَايَا كَمَا نَقَّيْتَ الثَّوْبَ الأَبْيَضَ مِنَ الدَّنَس ، وَأَبدلْهُ دَاراً خَيْراً مِنْ دَارِه ، وَأَهْلاً خَيراً مِنْ أَهْلِهِ ، وَزَوْجَاً خَيْراً مِنْ زَوْجِهِ ، وَأَدْخِلهُ الجَنَّةَ ، وَأَعِذْهُ مِنْ عَذَابِ القَبْرِ ، وَمِنْ عَذَابِ النَّارِ "

"ឱអល់ឡោះ! សូមអភ័យទោសដល់គាត់ អាណិតស្រលាញ់គាត់ ផ្តល់សុវត្ថិភាព ដល់គាត់ អធ្យាស្រ័យដល់គាត់ ផ្តល់កិត្តិយសដល់ការស្នាក់នៅរបស់គាត់ ធ្វើអោយផ្នូររបស់គាត់ធំទូលាយ លាងសំអាតគាត់នឹងទឹក ព្រិល និងព្រិលទឹកកក សំអាតគាត់អំពីបាបកម្មដូចដែលទ្រង់សំអាតក្រណាត់ពណ៌សអំពីកំអែល។ សូម ទ្រង់ផ្លាស់ប្តូរអោយគាត់នូវលំនៅឋានដែលល្អជាងលំនៅឋានពីមុនរបស់គាត់ គ្រួសារដែលល្អជាងគ្រួសាររបស់គាត់ ភរិយាដែលល្អជាងភរិយារបស់គាត់។ សូម ទ្រង់បញ្ចូលលគាត់ទៅក្នុងឋានសួគ៌ ហើយបញ្ចៀសគាត់អំពីទណ្ឌកម្មនៅក្នុងផ្នូរ និង ក្នុងឋាននរក" (លោកបានសូត្រនូវការបួងសួងនេះ) រហូតធ្វើអោយខ្ញុំប្រាថ្នាចង់ ក្លាយជាសពនោះ។

(សំរាប់បាបកម្ម خَطَايَا)

(Riyad as-Salihin 935)

Caption

" اللَّهُمَّ اغْفِرْ لِحَيِّنَا وَمَيِّتِنَا ، وَصَغِيرنَا وَكَبِيرنَا ، وَذَكَرِنَا وَأُنْثَانَا ، وشَاهِدِنَا وَغَائِبِنَا ، اللَّهُمَّ مَنْ أَحْيَيْتَهُ مِنَّا فَأَحْيِهِ عَلَى الإِسْلاَمِ ، وَمَنْ تَوَفَّيْتَهُ مِنَّا فَتَوفَّهُ عَلَى الإيمَان ، اللَّهُمَّ لا تَحْرِمْنَا أَجْرَهُ ، وَلا تَفْتِنَّا بَعدَهُ "

"ឱអល់ឡោះ! សូមអភ័យទោសដល់អ្នកនៅរស់ និងអ្នកស្លាប់នៃពួកយើង ក្មេងៗ និងមនុស្សចាស់នៃពួកយើង បុរស និងស្ត្រីនៃពួកយើង អ្នកមានវត្តមាននៅទីនេះ និងអ្នកមិននៅទីនេះនៃពួកយើង។ ឱអល់ឡោះ! អ្នកដែលទ្រង់ផ្តល់ជីវិតរស់នៅ នៃពួកយើង សូមទ្រង់បង្រស់គាត់ក្នុងភាពជាអ្នកអ៊ីស្លាម ហើយអ្នកដែលទ្រង់ ដកហូតជីវិតក្នុងចំណោមពួកយើង សូមទ្រង់ដកហូតជីវិតគាត់ក្នុងនាមជាអ្នក មានជំនឿ។ឱអល់ឡោះ!សូមទ្រង់កុំហាមឃាត់ពួកយើងអំពីផលបុណ្យរបស់គាត់ (ផលបុណ្យនៃការអត់ធ្មត់ពេលបាត់បង់គាត់)ហើយសូមទ្រង់កុំសាកល្បងពួកយើង អោយវង្វេងបន្ទាប់ពីការស្លាប់របស់គាត់។

(Riyad as-Salihin 936)

اللَّهُمَّ أَنْتَ رَبُّهَا ، وَأَنْتَ خَلَقْتَهَا ، وَأَنت هَدَيْتَهَا لِلإِسْلاَمِ ، وَأَنت قَبَضْتَ رُوحَهَا ، وَأَنْتَ أَعْلَمُ " بِسرِّهَا وَعَلاَنِيَتِهَا ، جِئنَا شُفَعَاءَ لَهُ ، فَاغْفِرْ لَهُ "

"ឱអល់ឡោះ! ទ្រង់ជាម្ចាស់របស់គាត់ ទ្រង់ជាអ្នកបង្កើតគាត់ ទ្រង់ជាអ្នកចង្អុល បង្ហាញគាត់អោយប្រកាន់នូវសាសនាអ៊ីស្លាម ទ្រង់ជាអ្នកដកហូតជីវិតរបស់គាត់ ទ្រង់គឺជាអ្នកដឹងអំពីអាថ៌កំបាំង និងការលាតត្រដាងរបស់គាត់ ពេលនេះពួកយើង មកជួបទ្រង់ដោយសុំអន្តរាគមចំពោះគាត់ ហេតុនេះ សូមទ្រង់អភ័យទោសដល់ គាត់ផង"

(Riyad as-Salihin 938)

អំពីវ៉ាស្ទីឡះ ពិន អាល់អាស្សក៏ رضي الله عنه ថា : ខ្ញុំបានលឺរ៉សូលុលឡោះ ﷺ ពេលសឡាតធ្វើជាអ៊ីម៉ាំពួកយើង អោយសាកសពបុរសម្នាក់នៃអ្នកអ៊ីស្លាមបានសូត្រថា:

اللَّهُمَّ إنَّ فُلانَ ابْنَ فُلانٍ في ذِمَّتِكَ وَحَبْلِ جِوَارِكَ ، فَقِهِ فِتْنَةَ القَبْرِ ، وَعذَابَ النَّارِ ، وَأَنْتَ أَهْلُ " الوَفَاءِ وَالحَمْدِ ؛ اللَّهُمَّ فَاغْفِرْ لَهُ وَارْحَمْهُ ، إنَّكَ أَنْتَ الغَفُورُ الرَّحيمُ "

"ឱអល់ឡោះ! ម្នាក់នេះ(ឈ្មោះ) កូន ម្នាក់នេះ(ឈ្មោះ)ស្ថិតនៅក្នុងការការពារ របស់ទ្រង់ និងការសុំជ្រកកោណអំពីទ្រង់ ហេតុនេះ សូមទ្រង់ការពារគាត់អំពី ការសាកល្បង(ការសួរសំណួរ) នៅក្នុងផ្នូរ និងទណ្ឌកម្មក្នុងឋាននរកផង ទ្រង់ គឺជាអ្នកអនុវត្តតាមការសន្យានិងត្រូវគេកោតសរសើរ។ឱអល់ឡោះ! សូមអភ័យ ទោសដល់គាត់ និងអាណិតស្រលាញ់គាត់ ពិតណាស់ទ្រង់គឺជាអ្នកអភ័យទោស និងអាណិតស្រលាញ់បំផុត"

Caption

(Riyad as-Salihin 939)

12.

اللَّهُمَّ إِنِّي أَسْأَلُكَ يَا اللهُ بِأَنَّكَ الْوَاحِدُ الأَحَدُ الصَّمَدُ الَّذِي لَمْ يَلِدْ وَلَمْ يُولَدْ وَلَمْ يَكُنْ لَهُ كُفُوًا أَحَدٌ أَنْ تَغْفِرَ لِي ذُنُوبِي إِنَّكَ أَنْتَ الْغَفُورُ الرَّحِيمُ .

(សំរាប់បាបកម្ម ذَنب)

(Sunan an-Nasa'i 1301)

13.

" اللَّهُمَّ بَرِّدْ قَلْبِي بِالثَّلْجِ وَالْبَرَدِ وَالْمَاءِ الْبَارِدِ اللَّهُمَّ نَقِّ قَلْبِي مِنَ الْخَطَايَا كَمَا نَقَّيْتَ الثَّوْبَ الأَبْيَضَ مِنَ الدَّنَسِ "

(សំអាប់បាបកម្ម خَطَايَا)

(Jami` at-Tirmidhi 3547)

Caption